## អំពើអមនុស្សធម៌ (inhuman acts/treatment)

អំពីអមនុស្សធម៌ផ្សេងទៀត ជាប្រភេទបទល្មើសនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity)។ ទង្វើជាច្រើន អាចត្រូវបានរាប់បញ្ចូលក្នុងចំណាងជើងនេះ។ វាជាខ្លឹមសារបើកចំហ ក្រៅពី អ្វីដែលជាបទល្មើសជាក់លាក់ត្រូវបានចែង ដូចជា មនុស្សឃាត (murder) ការសម្លាប់រង្គាល (extermination) ការបណ្ដេញចេញ (deportation) ការធ្វើជាទាសករ (enslavement) ការដាក់ក្នុងពន្ធនាគារ (imprisonment) រំលោភសេពសន្ថវៈ (rape) និង ការធ្វើទុក្ខបុកម្នេញ (persecution)។ ចៅក្រម ទទួលស្គាល់ថា មានភាពមិនច្បាស់លាស់នេះ អាចនាំឲ្យបំពានគោលការណ៍ជាក់លាក់នៃច្បាប់ព្រហ្មទណ្ឌ (specificity of criminal law)។ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p.448)។

**ខ្លឹមសារបន្ថែម៖** មាត្រា៧នៃ ICC ចែងអំពីអំពើអនុស្សធម៌ដទៃទៀត។ ក្នុងវិស័យសិទ្ធិមនុស្ស វាមានសញ្ញាណខុសគ្នារវាងទារុណកម្ម (torture) និងអំពើអមនុស្សធម៌ ដោយផ្ដោតទៅលើកម្រិតនៃការឈឺចាប់ (level of suffering)។ បន្ថែមពីលើនេះ អ្វីជាអំពើអមនុស្សធម៌ ក្នុងន័យសាមញ្ញ ជាអ្វីដែលមិនគួរធ្វើចំពោះមនុស្ស ដែលមិនមែនជាសត្វ។ ក្នុងន័យនេះ ការបញ្ជាឲ្យមនុស្ស លូនក្រោមជើងដូចសត្វឆ្កែ ជាអំពើអមនុស្សធម៌។